ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ព្រឹទ្ធសភា
អគ្គលេខាធិការដ្ឋាន

# របាយការណ៍
# ស្តីពី
# លទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំខែមីនា និងទិសដៅការងារខែមេសា ឆ្នាំ២០២៥

នៅក្នុងខែមីនា ឆ្នាំ២០២៥ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានបំពេញការងារលើគ្រប់វិស័យ ដើម្បីផ្តល់សេវាជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា ក្នុងការអនុវត្តមុខងាររបស់ខ្លួនប្រកប ដោយស្មារតីទទួលខុសត្រូវខ្ពស់ ទទួលបានលទ្ធផលដូចខាងក្រោម៖

## I-លទ្ធផលការងារសម្រេចបានលើមុខងារទាំង៥

### ១-មុខងារតាមដានការអនុវត្តច្បាប់

- បានរៀបចំចាត់ចែង និងផ្តល់សេវាជូនគណៈកម្មការនានារបស់ព្រឹទ្ធសភា អញ្ជើញចុះបំពេញ បេសកកម្ម នៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្តនានា រួមមាន៖
  - ❖ គណៈកម្មការទី៤ព្រឹទ្ធសភា៖
    - បានអញ្ជើញចុះជួបពិភាក្សាការងារជាមួយអាជ្ញាធរខេត្តព្រះវិហារ ដើម្បីឈ្វេងយល់អំពី ប្រសិទ្ធភាពក្នុងការអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធលើកិច្ចប្រតិបត្តិការ និង
    - បានអញ្ជើញជួបពិភាក្សាការងារជាមួយ **ឯកឧត្តមអភិសន្តិបណ្ឌិត ស សុខា** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ដើម្បីឈ្វេងយល់អំពីវឌ្ឍនភាពការងារ និងទិសដៅការងារបន្ត របស់ក្រសួងឆ្នាំ២០២៥ នៅទីស្តីការក្រសួងមហាផ្ទៃ។
  - ❖ គណៈកម្មការទី៧ព្រឹទ្ធសភា៖
    - បានអញ្ជើញចុះបំពេញបេសកកម្ម ដើម្បីឈ្វេងយល់អំពីវឌ្ឍនភាពការងារ បញ្ហាប្រឈម វិធានការ និងចក្ខុវិស័យពាក់ព័ន្ធវិស័យជាសមត្ថកិច្ចរបស់គណៈកម្មការ នៅខេត្តមណ្ឌលគិរី ខេត្តរតនគិរី និងខេត្តស្ទឹងត្រែង និង
    - បានអញ្ជើញជួបពិភាក្សាការងារជាមួយ **ឯកឧត្តម ហួត ហាក់** រដ្ឋមន្ត្រីក្រសួងទេសចរណ៍ ដើម្បីឈ្វេងយល់អំពីវឌ្ឍនភាពការងារ បញ្ហាប្រឈម វិធានការ និងចក្ខុវិស័យរបស់ក្រសួង នៅសាលប្រជុំក្រសួងទេសចរណ៍។

❖ គណៈកម្មការទី៩ព្រឹទ្ធសភាៈ

- បានអញ្ជើញចុះបំពេញបេសកកម្ម ដើម្បីឈ្វេងយល់អំពីដំណើរការប្រតិបត្តិនៃទំនប់វារីអគ្គិសនីសេសានក្រោម២ ស្ថានីយផលិតថាមពលអគ្គិសនីដើរដោយពន្លឺព្រះអាទិត្យ ព្រមទាំងវឌ្ឍនភាពការងារដែលអាជ្ញាធរខេត្តសម្រេចបាន បញ្ហាប្រឈម និងផែនការសកម្មភាពរបស់អាជ្ញាធរខេត្ត និងការអនុវត្តគោលនយោបាយភូមិ ឃុំ សង្កាត់ មានសុវត្ថិភាព នៅខេត្តស្ទឹងត្រែង និងខេត្តកំពង់ស្ពឺ និង
- បានអញ្ជើញជួបពិភាក្សាការងារជាមួយថ្នាក់ដឹកនាំក្រសួងពាណិជ្ជកម្ម អំពីវឌ្ឍនភាពការងារ បញ្ហាប្រឈម និងផែនការសកម្មភាព នៅទីស្តីការក្រសួងពាណិជ្ជកម្ម។

## ២-មុខងារតំណាង

- បានរៀបចំចាត់ចែង និងផ្តល់សេវាជូនប្រមុខរដ្ឋស្តីទី និងថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភាៈ

❖ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ប្រមុខរដ្ឋស្តីទី** បានអញ្ជើញចូលរួមពិធីនានា នៅរាជធានីភ្នំពេញ ចំនួន៣លើក រួមមានៈ

- បានអញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់ក្នុងពិធីបំពាក់ឋានន្តរសក្តិ ថ្នាក់ នាយឧត្តមសេនីយ៍ ផុតលេខ ផ្កាយមាស៥ ជូន **សម្តេចពិជ័យសេនា ទៀ បាញ់** និង**សម្តេចកិត្តិសង្គហបណ្ឌិត ម៉ែន សំអន** នៅវិមានសន្តិភាព។
- បានអញ្ជើញរៀបចំចាត់ចែងពិធីបុណ្យសព **ឯកឧត្តមអ្នកឧកញ៉ាឧត្តមមេត្រីវិសិដ្ឋ ហ៊ុន សាន** រដ្ឋលេខាធិការក្រសួងសាធារណការ និងដឹកជញ្ជូន និងជាបងប្រុសបង្កើត **សម្តេចតេជោ** នៅខណ្ឌទួលគោក រាជធានីភ្នំពេញ និង
- បានអញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់ក្នុងពិធីពិសាភោជនាហារសាមគ្គីនៃគ្រួសារសមាគមឧកញ៉ាកម្ពុជា ក្នុងឱកាសនៃពិធីបិទសន្និបាតប្រចាំឆ្នាំបូកសរុបលទ្ធផលការងារឆ្នាំ២០២៤ និងទិសដៅការងារឆ្នាំ២០២៥ របស់សមាគមឧកញ៉ាកម្ពុជា នៅដីព្រីមៀរសេនជីសែនសុខ រាជធានីភ្នំពេញ។

❖ **ឯកឧត្តម អ៊ុច បូរិទ្ធ** ប្រធានស្តីទីព្រឹទ្ធសភាបានៈ

- បដិសណ្ឋារកិច្ចភ្ញៀវជាតិៈ
  - ជាតំណាងដ៏ខ្ពង់ខ្ពស់របស់ **សម្តេចតេជោ ប្រធានព្រឹទ្ធសភា** ទទួលជួបគណៈប្រតិភូនារី ដឹកនាំដោយ **លោកជំទាវកិត្តិបណ្ឌិត អ៊ឹង កន្ថាផាវី** រដ្ឋមន្ត្រីក្រសួងកិច្ចការនារី ចំនួន ២៥០នាក់ ចូលជួបសម្តែងការគួរសម ក្នុងឱកាសអបអរសាទរខួបលើកទី១១៤ (១៩១១-២០២៥) ទិវាអន្តរជាតិនារី ៨ មីនា ក្រោមប្រធានបទ "សិទ្ធិ សមភាព និងភាពអង់អាច ចំពោះស្ត្រី និងក្មេងស្រីគ្រប់រូប" នៅវិមាន៧មករា។
- សកម្មភាពចុះមូលដ្ឋានៈ
  - បានអញ្ជើញចុះជួបសំណេះសំណាលជាមួយមន្ត្រីរាជការ និងកងកម្លាំងប្រដាប់អាវុធ និងអាជ្ញាធរមូលដ្ឋានស្រុក ក្នុងស្រុកបាធាយ ខេត្តកំពង់ចាម សរុបចំនួន៤៨៥នាក់ និង

- បានអញ្ជើញចុះជួបសំណេះសំណាលជាមួយសមាជិកក្រុមប្រឹក្សាឃុំ ស្មៀនឃុំ នាយប៉ុស្តិ៍នគរបាល ប្រធានមណ្ឌលសុខភាព ក្នុងឃុំទាំង៧នៃស្រុកក្រូចឆ្មារ និងឃុំទាំង៧នៃស្រុកតំបែរ ខេត្តត្បូងឃ្មុំ ព្រមទាំងអាជ្ញាធរពាក់ព័ន្ធ សរុបចំនួន២១៧នាក់។

▪ សកម្មភាពចូលរួមពិធីផ្សេងៗ៖

- បានអញ្ជើញចូលរួមជាភ្ញៀវកិត្តិយសក្នុងពិធីបំពាក់ឋានន្តរសក្តិ ថ្នាក់ នាយឧត្តមសេនីយ៍ ផុតលេខ ផ្កាយមាស៥ ជូន **សម្តេចពិជ័យសេនា ទៀ បាញ់** និង**សម្តេចកិត្តិសង្គហបណ្ឌិត ម៉ែន សំអន** ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ប្រមុខរដ្ឋស្តីទី** នៅវិមានសន្តិភាព។
- បានអញ្ជើញដឹកនាំគណៈប្រតិភូព្រឹទ្ធសភា គោរពវិញ្ញាណក្ខន្ធសព **ឯកឧត្តមអ្នកឧកញ៉ា ឧត្តមមេត្រីវិសិដ្ឋ ហ៊ុន សាន** រដ្ឋលេខាធិការក្រសួងសាធារណការ និងដឹកជញ្ជូន និងជាបងប្រុសបង្កើត **សម្តេចតេជោ** នៅខណ្ឌទួលគោក រាជធានីភ្នំពេញ។
- បានអញ្ជើញចូលរួមក្នុងពិធីពិសាភោជនាហារសាមគ្គីនៃគ្រួសារសមាគមឧកញ៉ាកម្ពុជា ក្នុងឱកាសនៃពិធីបិទសន្និបាតប្រចាំឆ្នាំបូកសរុបលទ្ធផលការងារឆ្នាំ២០២៤ និងទិសដៅការងារឆ្នាំ២០២៥ របស់សមាគមឧកញ៉ាកម្ពុជា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ប្រមុខរដ្ឋស្តីទី** និងជាប្រធានកិត្តិយស "សមាគមឧកញ៉ាកម្ពុជា" នៅដីព្រីមៀរសេនជីសែនសុខ រាជធានីភ្នំពេញ។
- បានអញ្ជើញជួបសំណេះសំណាលជាមួយសមាជិកាព្រឹទ្ធសភា មន្ត្រីរាជការជាស្ត្រី និងនិវត្តជនជាស្ត្រីនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ក្នុងឱកាសអបអរសាទរខួបលើកទី១១៤ (១៩១១-២០២៥) ទិវាអន្តរជាតិនារី ៨ មីនា ក្រោមប្រធានបទ "សិទ្ធិ សមភាព និងភាពអង់អាច ចំពោះស្ត្រី និងក្មេងស្រីគ្រប់រូប" នៅសាលសិក្ខាសាលាខាងជើងវិមានព្រឹទ្ធសភា និង
- បានអញ្ជើញចូលរួមពិសាអាហារបិទសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០២៤ និងទិសដៅការងារឆ្នាំ២០២៥ របស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ នៅសណ្ឋាគារសុខាភ្នំពេញ។

❖ **ឯកឧត្តមបណ្ឌិត ឆន់ ទឡ្ហនា** អនុប្រធានទី២ព្រឹទ្ធសភាបាន៖

▪ សកម្មភាពចុះមូលដ្ឋាន៖

- បានអញ្ជើញចុះជួបសំណេះសំណាលជាមួយសមាជិកក្រុមប្រឹក្សាសង្កាត់ អាជ្ញាធរមូលដ្ឋាន និងអ្នកពាក់ព័ន្ធ សរុបចំនួន១៣២នាក់ មកពី២៥សង្កាត់នៃខណ្ឌជ្រោយចង្វារ ខណ្ឌច្បារអំពៅ ខណ្ឌឫស្សីកែវ និងខណ្ឌព្រែកព្នៅ នៅសាលប្រជុំសាលាខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ។

- សកម្មភាពចូលរួមពិធីផ្សេងៗ៖
  - បានអញ្ជើញចូលរួមជាភ្ញៀវកិត្តិយសក្នុងពិធីបំពាក់ឋានន្តរសក្តិ ថ្នាក់ នាយឧត្តមសេនីយ៍ ផុតលេខ ផ្កាយមាស៥ ជូន **សម្តេចពិជ័យសេនា ទៀ បាញ់** និង**សម្តេចកិត្តិសង្គហបណ្ឌិត ម៉ែន សំអន** ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ប្រមុខរដ្ឋស្តីទី** នៅវិមានសន្តិភាព។
  - បានអញ្ជើញចូលរួមក្នុងពិធីបុណ្យទន្លេលើកទី៩ ឆ្នាំ២០២៥ ក្រោមប្រធានបទ គុណតម្លៃនៃទន្លេ៖ ផ្សារភ្ជាប់វប្បធម៌ និងទេសចរណ៍ធម្មជាតិ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី**នៃព្រះរាជាណាចក្រកម្ពុជា នៅបឹងតាកែវ ក្រុងដូនកែវ ខេត្តតាកែវ។
  - បានអញ្ជើញជាអធិបតីក្នុងសិក្ខាសាលាជម្រាបជូនឯកអគ្គរាជទូត ឯកអគ្គរដ្ឋទូត និងប្រធានបេសកកម្មការទូតប្រចាំព្រះរាជាណាចក្រកម្ពុជា ស្តីពី សមិទ្ធផលការទូតសភារបស់ព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា នីតិកាលទី៥ នៅក្នុងឆ្នាំ២០២៤ នៅសាលសិក្ខាសាលាខាងជើង វិមានព្រឹទ្ធសភា និងពិធីលៀងសាយភោជន៍ជូនអង្គទូតទាំងអស់នៅសណ្ឋាគារហ៊ីម៉ាវ៉ារី រាជធានីភ្នំពេញ។
  - ជាតំណាងដ៏ខ្ពង់ខ្ពស់របស់ **សម្តេចតេជោ ប្រធានព្រឹទ្ធសភា** ថ្លែងសុន្ទរកថាបិទសិក្ខាសាលាស្តីពី ប្រាក់រៀល ប្រព័ន្ធបាគង និងខេអេចឃ្យូអរ (KHQR) និងពិធីអបអរសាទរទិវាប្រាក់រៀល ខួបលើកទី៤៥ នៃការដាក់ឱ្យចរាចរប្រាក់រៀលឡើងវិញ (២០ មីនា ១៩៨០ - ២០ មីនា ២០២៥) ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចមហារដ្ឋសភាធិការធិបតី ឃួន សុដារី** ប្រធានរដ្ឋសភា នៅវិមានរដ្ឋសភា។
  - បានអញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់ក្នុងពិធីក្រុងពាលី និងចុះអនុស្សរណៈសាងសង់អគារសិក្សា១ខ្នង មានចំនួន៥បន្ទប់ ដែលជាអំណោយរបស់សមាគមមូលនិធិទូទៅដើម្បីសុខុមាលភាពជាតិ និងជួយគ្នាទៅវិញទៅមក របស់ប្រទេសជប៉ុន នៅសាលាបឋមសិក្សាក្រចាប ស្រុកស្វាយអន្ទរ ខេត្តព្រៃវែង។
  - បានអញ្ជើញដឹកនាំក្រុមគ្រូពេទ្យពិនិត្យមាត់ធ្មេញដល់សិស្សានុសិស្ស ព្រមទាំងចែកប្រាសដុសធ្មេញ ថ្នាំដុសធ្មេញ សម្ភារសិក្សា និងទូរទស្សន៍ នៅសាលាបឋមសិក្សាកំពង់ស្វាយ រួមទាំងប្រគេនចង្ហាន់ព្រះសង្ឃក្នុងវត្តកំពង់ស្វាយ ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ។
  - បានអញ្ជើញសួរសុខទុក្ខ **ឯកឧត្តម ទឹម ផន** លេខាធិការគណៈកម្មការទី៩ព្រឹទ្ធសភា និងជាសមាជិកក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៦ ដែលកំពុងសម្រាកព្យាបាលជំងឺនៅគេហដ្ឋាន ក្នុងបុរីជីបម៉ុងលែន សង្កាត់បាក់ខែង ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ។
  - បានអញ្ជើញចូលរួមអម **ឯកឧត្តម អ៊ុច បូរិទ្ធ** ប្រធានស្តីទីព្រឹទ្ធសភា ដឹកនាំគណៈប្រតិភូព្រឹទ្ធសភា គោរពវិញ្ញាណក្ខន្ធសព **ឯកឧត្តមអ្នកឧកញ៉ាឧត្តមមេត្រីវិសិដ្ឋ ហ៊ុន សាន**

រដ្ឋលេខាធិការក្រសួងសាធារណការ និងដឹកជញ្ជូន និងជាបងប្រុសបង្កើត **សម្តេចតេជោ** នៅខណ្ឌទួលគោក រាជធានីភ្នំពេញ។

- បានអញ្ជើញគោរពវិញ្ញាណក្ខន្ធសព **លោក ថេង រាមរិច្ឆធិរាជ** កូនប្រុសបង្កើតរបស់ **លោក ថេង សុថុល** អភិបាលនៃគណៈអភិបាលខណ្ឌ៧មករា នៅខណ្ឌសែនសុខ រាជធានីភ្នំពេញ និង
- បានអញ្ជើញរៀបចំពិធីពិសាអាហារសាមគ្គី ក្នុងឱកាសអបអរសាទរបុណ្យចូលឆ្នាំថ្មី ប្រពៃណីជាតិខ្មែរ ឆ្នាំម្សាញ់ សប្តស័ក ពុទ្ធសករាជ ២៥៦៩ ដោយមានការអញ្ជើញចូលរួមពីគណៈកម្មការទាំង១០ព្រឹទ្ធសភា នៅភោជនីយដ្ឋាន Farm Kafe វិទ្យាស្ថានជាតិកសិកម្មព្រែកលៀប។

❖ **សមាជិក សមាជិកាព្រឹទ្ធសភា៖**

- បានអញ្ជើញចូលរួមក្នុងសិក្ខាសាលាស្តីពី ប្រាក់រៀល ប្រព័ន្ធបាគង និងខេអេចឃ្យូអរ (KHQR) និងពិធីអបអរសាទរទិវាប្រាក់រៀល ខួបលើកទី៤៥ នៃការដាក់ឱ្យចរាចរប្រាក់រៀលឡើងវិញ (២០ មីនា ១៩៨០ - ២០ មីនា ២០២៥) ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចមហារដ្ឋសភាធិការធិបតី ឃួន សុដារី** ប្រធានរដ្ឋសភា នៅវិមានរដ្ឋសភា។
- បានអញ្ជើញចូលរួមវេទិកាផ្សព្វផ្សាយស្តីពី វឌ្ឍនភាពវិស័យឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍តាមរយៈការអនុវត្តយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ របស់រាជរដ្ឋាភិបាល នីតិកាលទី៧នៃរដ្ឋសភា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចមហារដ្ឋសភាធិការធិបតី ឃួន សុដារី** ប្រធានរដ្ឋសភា នៅវិមានរដ្ឋសភា។
- បានអញ្ជើញចូលរួមអបអរសាទរខួបលើកទី១១៤ (១៩១១-២០២៥) ទិវាអន្តរជាតិនារី ៨ មីនា ក្រោមប្រធានបទ "សិទ្ធិ សមភាព និងភាពអង់អាច ចំពោះស្ត្រី និងក្មេងស្រីគ្រប់រូប" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម អ៊ុច បូរិទ្ធ** អនុប្រធានទី១ព្រឹទ្ធសភា នៅសាលសិក្ខាសាលាខាងជើង វិមានព្រឹទ្ធសភា។
- បានអញ្ជើញចូលរួមសិក្ខាសាលាជម្រាបជូនឯកអគ្គរាជទូត ឯកអគ្គរដ្ឋទូត និងប្រធានបេសកកម្មការទូតប្រចាំព្រះរាជាណាចក្រកម្ពុជា ស្តីពី សមិទ្ធផលការទូតសភារបស់ព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា នីតិកាលទី៥ នៅក្នុងឆ្នាំ២០២៤ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមបណ្ឌិត ធន់ វឌ្ឍនា** អនុប្រធានទី២ព្រឹទ្ធសភា នៅសាលសិក្ខាសាលាខាងជើង វិមានព្រឹទ្ធសភា និងពិធីលៀងសាយភោជន៍ជូនអង្គទូតទាំងអស់ នៅសណ្ឋាគារហ៊ីម៉ាវ៉ារី រាជធានីភ្នំពេញ។
- បានអញ្ជើញចូលរួមកិច្ចប្រជុំជាមួយគណៈកម្មការទី៩រដ្ឋសភា និងក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ដើម្បីត្រៀមរៀបចំវេទិកាផ្សព្វផ្សាយស្តីពី វឌ្ឍនភាពនៃវិស័យឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា នវានុវត្តន៍តាមរយៈការអនុវត្តយុទ្ធសាស្ត្រ

បញ្ចកោណដំណាក់កាលទី១ របស់រាជរដ្ឋាភិបាល នីតិកាលទី៧នៃរដ្ឋសភា នៅវិមានរដ្ឋសភា។

- បានអញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីក្រុងពាលី និងចុះអនុស្សរណៈសាងសង់អគារសិក្សា១ខ្នង មានចំនួន៥បន្ទប់ ដែលជាអំណោយរបស់សមាគមមូលនិធិទូទៅ ដើម្បីសុខុមាលភាពជាតិ និងជួយគ្នាទៅវិញទៅមក របស់ប្រទេសជប៉ុន ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមបណ្ឌិត ធន់ វឌ្ឍនា** អនុប្រធានទី២ព្រឹទ្ធសភា នៅសាលាបឋមសិក្សាក្រចាប ស្រុកស្វាយអន្ទរ ខេត្តព្រៃវែង។
- បានអញ្ជើញចូលរួមពិធីបិទសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០២៤ របស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមសន្តិបណ្ឌិត នេត សាវឿន** ឧបនាយករដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន នៅទីស្តីការក្រសួងមហាផ្ទៃ។
- បានអញ្ជើញដឹកនាំក្រុមគ្រូពេទ្យស្ម័គ្រចិត្តនៃសមាគមបេសកកម្មមនុស្សធម៌របស់សាធារណរដ្ឋបារាំង នៅកម្ពុជា (AMH) ចុះពិនិត្យព្យាបាលជំងឺ ជូនប្រជាពលរដ្ឋដោយឥតគិតថ្លៃ នៅសាលាបឋមសិក្សាព្រែកតាពាត់ ខណ្ឌជ្រោយចង្វារ សាលាបឋមសិក្សាភូមិធំ ខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ មន្ទីរពេទ្យបង្អែកព្រះនរោត្តមសីហនុត្បូងឃ្មុំ មន្ទីរពេទ្យបង្អែកស្រុកអូររាំងឪ ខេត្តត្បូងឃ្មុំ និងនៅវត្តអន្លង់តាអ៊ួរ ខេត្តបាត់ដំបង។
- បានអញ្ជើញចូលរួមជាកិត្តិយសក្នុងព្រឹត្តិការណ៍បាល់ទាត់មិត្តភាពកម្ពុជា-ថៃ ដើម្បីអបអរសាទរខួបលើកទី៧៥ នៃការបង្កើតទំនាក់ទំនងការទូតរវាងព្រះរាជាណាចក្រកម្ពុជា និងព្រះរាជាណាចក្រថៃឡង់ដ៏ នៅពហុកីឡដ្ឋានជាតិអូឡាំពិក រាជធានីភ្នំពេញ។
- បានអញ្ជើញធ្វើបទបង្ហាញជូនលោកគ្រូ អ្នកគ្រូ សិស្សានុសិស្សនៃសាលាបញ្ញាសាស្ត្រអន្តរជាតិ ចំនួន៥១នាក់ មកទស្សនកិច្ចសិក្សាឈ្វេងយល់អំពីរចនាសម្ព័ន្ធ តួនាទី ភារកិច្ចរបស់ព្រឹទ្ធសភា នៅសាលសិក្ខាសាលាខាងជើង វិមានព្រឹទ្ធសភា។
- បានអញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីផ្សេងៗ **ចំនួន៧លើក** ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី**នៃព្រះរាជាណាចក្រកម្ពុជា រួមមាន៖
  - ១/ វេទិការវាងរាជរដ្ឋាភិបាល និងរដ្ឋបាលថ្នាក់ក្រោមជាតិស្តីពី កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ដើម្បីចូលរួមសម្រេចបានចក្ខុវិស័យកម្ពុជា ឆ្នាំ២០៥០។
  - ២/ ពិធីបើកសន្និសីទចក្ខុវិស័យប្រទេសកម្ពុជា ឆ្នាំ២០២៥ លើប្រធានបទ ការសម្រេចបានចក្ខុវិស័យអភិវឌ្ឍន៍របស់កម្ពុជា ប្រកបដោយចីរភាព បរិយាបន្ន និងភាពធន់៖ គោលនយោបាយ និងយុទ្ធសាស្ត្រកំណើនមានគុណភាពរយៈពេលវែងក្នុងបរិការណ៍ដែលមានភាពមិនច្បាស់លាស់របស់វិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវ ដើម្បីអភិវឌ្ឍន៍កម្ពុជា។

៣/ ព្រះរាជពិធីស្រោចស្រពព្រះសុគន្ធវារីថ្វាយសម្ដេចព្រះអគ្គមហាសង្ឃរាជ សម្ដេចព្រះសង្ឃនាយក សម្ដេចព្រះសង្ឃនាយករងទី១ សម្ដេចព្រះសង្ឃនាយករងទី២ សម្ដេចព្រះសង្ឃនាយករងទី៣ និងសម្ដេចព្រះសង្ឃនៃគណៈមហានិកាយនៃព្រះរាជាណាចក្រកម្ពុជា។

៤/ ពិធីបិទសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០២៤ និងទិសដៅការងារឆ្នាំ២០២៥ របស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ។

៥/ ពិធីបុណ្យទន្លេលើកទី៩ ឆ្នាំ២០២៥ ក្រោមប្រធានបទ គុណតម្លៃនៃទន្លេ៖ ផ្សារភ្ជាប់វប្បធម៌ និងទេសចរណ៍ធម្មជាតិ។

៦/ ពិធីប្រគល់សញ្ញាបត្រ ថ្នាក់បរិញ្ញាបត្ររង ថ្នាក់បរិញ្ញាបត្រ និងថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ជូនដល់និស្សិតនៃវិទ្យាស្ថាន វ៉ាន់ ដា និង

៧/ កិច្ចប្រជុំកំពូលឥស្លាម រៀបចំដោយអង្គការសម្ព័ន្ធពិភពលោកឥស្លាម ក្រោមប្រធានបទ ឥស្លាម និងពុទ្ធសាសនា នៅរាជធានីភ្នំពេញ និងខេត្តតាកែវ។

❖ ដោយឡែក សមាជិក សមាជិកាព្រឹទ្ធសភា បានអញ្ជើញចុះជួបសំណេះសំណាល សាកសួរសុខទុក្ខប្រជាពលរដ្ឋ ក្រុមប្រឹក្សាឃុំ សង្កាត់ ស្មៀន នាយប៉ុស្តិ៍នគរបាលរដ្ឋបាល និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ ដើម្បីពង្រឹងតួនាទី ភារកិច្ចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី៥ នៅមូលដ្ឋាន ឈ្វេងយល់អំពីវឌ្ឍនភាពការងារ ការងារសន្តិសុខ សណ្ដាប់ធ្នាប់ ការផ្ដល់សេវាសាធារណៈជូនប្រជាពលរដ្ឋ និងការអនុវត្តគោលនយោបាយភូមិ-ឃុំ មានសុវត្ថិភាព ពិនិត្យហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ ដោះស្រាយទុក្ខលំបាករបស់ប្រជាពលរដ្ឋ និងបញ្ហាប្រឈមនានា នៅរាជធានីភ្នំពេញ និងតាមបណ្ដាខេត្តនានា **ចំនួន១២០លើក** ព្រមទាំងបានអញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីសម្ពោធសមិទ្ធផលនានា និងពិធីផ្លូវការផ្សេងៗ **ចំនួន១២០លើក**។

- សកម្មភាពការងាររបស់ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា៖

❖ **ឯកឧត្តម ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភាបាន៖

- អញ្ជើញចូលរួមអម **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ប្រមុខរដ្ឋស្ដីទី** អញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់ក្នុងពិធីពិសាភោជនាហារសាមគ្គីនៃគ្រួសារសមាគមឧកញ៉ាកម្ពុជា ក្នុងឱកាសនៃពិធីបិទសន្និបាតប្រចាំឆ្នាំបូកសរុបលទ្ធផលការងារឆ្នាំ២០២៤ និងទិសដៅការងារឆ្នាំ២០២៥ របស់សមាគមឧកញ៉ាកម្ពុជា នៅដីព្រៃមៀរសេនជីសែនសុខ រាជធានីភ្នំពេញ។
- អញ្ជើញចូលរួមអម **ឯកឧត្តម អ៊ុច បូររិទ្ធ** ប្រធានស្ដីទីព្រឹទ្ធសភា ទទួលជួបសំណេះសំណាលជាមួយគណៈប្រតិភូនារី ដឹកនាំដោយ **លោកជំទាវកិត្តិបណ្ឌិត អ៊ឹង កន្ថាផាវី** រដ្ឋមន្ត្រីក្រសួងកិច្ចការនារី ចូលជួបសម្ដែងការគួរសម ក្នុងឱកាសអបអរសាទរខួបលើកទី១១៤ (១៩១១-២០២៥) ទិវាអន្តរជាតិនារី ៨ មីនា ក្រោមប្រធានបទ "សិទ្ធិ សមភាព និងភាពអង់អាច ចំពោះស្ត្រី និងក្មេងស្រីគ្រប់រូប" នៅវិមាន៧មករា។

- អញ្ជើញចូលរួមពិធីបើក និងបិទសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០២៤ និងទិសដៅការងារឆ្នាំ២០២៥ របស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ។
- អញ្ជើញចូលរួមរៀបចំចាត់ចែងដំណើរការពិធីបុណ្យសព **ឯកឧត្តមអ្នកឧកញ៉ាឧត្តមមេត្រីវិសិដ្ឋ ហ៊ុន សាន** រដ្ឋលេខាធិការក្រសួងសាធារណការ និងដឹកជញ្ជូន និងជាបងប្រុសបង្កើត **សម្ដេចតេជោ** នៅខណ្ឌទួលគោក រាជធានីភ្នំពេញ។
- អញ្ជើញចូលរួមទស្សនាព្រឹត្តិការណ៍កីឡាបាល់ទាត់មិត្តភាពកម្ពុជា-ថៃ ដើម្បីអបអរសាទរខួបអនុស្សាវរីយ៍លើកទី៧៥ នៃការបង្កើតទំនាក់ទំនងការទូតរវាងព្រះរាជាណាចក្រកម្ពុជា និងព្រះរាជាណាចក្រថៃឡង់ដ៍ នៅពហុកីឡដ្ឋានជាតិអូឡាំពិក រាជធានីភ្នំពេញ និង
- អញ្ជើញសួរសុខទុក្ខ **ឯកឧត្តម ទេព យុទ្ធី** លេខាធិការគណៈកម្មការទី៨ព្រឹទ្ធសភា កំពុងសម្រាកព្យាបាលជំងឺ នៅមន្ទីរពេទ្យកាល់ម៉ែត។

❖ **ឯកឧត្តម ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភា **ឯកឧត្តម ខេង សិទ្ធិគុណ ឯកឧត្តម អោក បូរ៉ា** និង**ឯកឧត្តម ឡោក ឆាយ** អគ្គលេខាធិការរងព្រឹទ្ធសភាបាន៖

- អញ្ជើញចូលរួមជាភ្ញៀវកិត្តិយសក្នុងពិធីបំពាក់ឋានន្តរសក្តិ ថ្នាក់ នាយឧត្តមសេនីយ៍ផុតលេខផ្កាយមាស៥ ជូន **សម្ដេចពិជ័យសេនា ទៀ បាញ់** និង**សម្ដេចកិត្តិសង្គហបណ្ឌិត ម៉ែន សំអន** ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ប្រមុខរដ្ឋស្ដីទី** នៅវិមានសន្តិភាព និង
- អញ្ជើញចូលរួមអម **ឯកឧត្តម អ៊ុច បូរិទ្ធ** ប្រធានស្តីទីព្រឹទ្ធសភា ដឹកនាំគណៈប្រតិភូព្រឹទ្ធសភា គោរពវិញ្ញាណក្ខន្ធសព **ឯកឧត្តមអ្នកឧកញ៉ាឧត្តមមេត្រីវិសិដ្ឋ ហ៊ុន សាន** រដ្ឋលេខាធិការក្រសួងសាធារណការ និងដឹកជញ្ជូន និងជាបងប្រុសបង្កើត **សម្ដេចតេជោ** នៅខណ្ឌទួលគោក រាជធានីភ្នំពេញ។

❖ **ឯកឧត្តម ខេង សិទ្ធិគុណ** និង**ឯកឧត្តម អោក បូរ៉ា** អគ្គលេខាធិការរងព្រឹទ្ធសភា បានអញ្ជើញចូលរួមពិធីជប់លៀងក្នុងឱកាសសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០២៤ និងទិសដៅការងារឆ្នាំ២០២៥ របស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ នៅសណ្ឋាគារសុខាភ្នំពេញ។

❖ **ឯកឧត្តម ខេង សិទ្ធិគុណ ឯកឧត្តម អោក បូរ៉ា** និង**ឯកឧត្តម ឡោក ឆាយ** អគ្គលេខាធិការរងព្រឹទ្ធសភាបាន៖

- អញ្ជើញចូលរួមពិធីសំណេះសំណាលអបអរសាទរខួបលើកទី១១៤ (១៩១១-២០២៥) ទិវាអន្តរជាតិនារី ៨ មីនា ក្រោមប្រធានបទ "សិទ្ធិ សមភាព និងភាពអង់អាច ចំពោះស្ត្រី និងក្មេងស្រីគ្រប់រូប" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម អ៊ុច បូរិទ្ធ** ប្រធានស្តីទីព្រឹទ្ធសភា នៅវិមាន៧មករា។
- អញ្ជើញចូលរួមសិក្ខាសាលាជម្រាបជូនឯកអគ្គរាជទូត ឯកអគ្គរដ្ឋទូត និងប្រធានបេសកកម្មការទូតប្រចាំព្រះរាជាណាចក្រកម្ពុជា ស្តីពី សមិទ្ធផលការទូតសភារបស់ព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា នីតិកាលទី៥ នៅក្នុងឆ្នាំ២០២៤ ក្រោមអធិបតីភាព

ដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមបណ្ឌិត ធន់ វឌ្ឍនា** អនុប្រធានទី២ព្រឹទ្ធសភា នៅសាលសិក្ខាសាលាខាងជើង វិមានព្រឹទ្ធសភា និងពិធីលៀងសាយភោជន៍ជូនអង្គទូតទាំងអស់ នៅសណ្ឋាគារហ៊ីម៉ាវ៉ារី រាជធានីភ្នំពេញ និង

- អញ្ជើញចូលរួមក្នុងពិធីសំណេះសំណាលជាមួយសមាជិកក្រុមប្រឹក្សាសង្កាត់ អាជ្ញាធរមូលដ្ឋាន មកពី២៥សង្កាត់នៃខណ្ឌជ្រោយចង្វារ ខណ្ឌច្បារអំពៅ ខណ្ឌឫស្សីកែវ និងខណ្ឌព្រែកព្នៅ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមបណ្ឌិត ធន់ វឌ្ឍនា** អនុប្រធានទី២ព្រឹទ្ធសភា និងជាប្រធានក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី១ នៅសាលប្រជុំសាលាខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ។

❖ **ឯកឧត្តម ខេង សិទ្ធិគុណ** អគ្គលេខាធិការរងព្រឹទ្ធសភាបាន៖

- អញ្ជើញចូលរួមសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០២៤ និងទិសដៅការងារឆ្នាំ២០២៥ របស់ក្រសួងមុខងារសាធារណៈ នៅដីព្រីមៀរសេនជីសែនសុខ រាជធានីភ្នំពេញ និង
- អញ្ជើញចូលរួមកិច្ចប្រជុំការងារសំខាន់ៗរបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា និងពិធីផ្សេងៗ ចំនួន៧លើក។

❖ **ឯកឧត្តម អោក បូរ៉ា** អគ្គលេខាធិការរងព្រឹទ្ធសភាបាន៖

- អញ្ជើញចូលរួមពិធីសំណេះសំណាលអបអរសាទរខួបលើកទី១១៤ (១៩១១-២០២៥) ទិវាអន្តរជាតិនារី ៨ មីនា ក្រោមប្រធានបទ "សិទ្ធិ សមភាព និងភាពអង់អាច ចំពោះស្ត្រី និងក្មេងស្រីគ្រប់រូប" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម អ៊ុច បូរិទ្ធ** ប្រធានស្តីទីព្រឹទ្ធសភា នៅសាលសិក្ខាសាលាខាងជើង វិមានព្រឹទ្ធសភា និង
- អញ្ជើញចូលរួមកិច្ចប្រជុំការងារសំខាន់ៗរបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា និងពិធីផ្សេងៗ ចំនួន៤លើក។

❖ **ឯកឧត្តម ឡោក ឆាយ** អគ្គលេខាធិការរងព្រឹទ្ធសភា បានអញ្ជើញចូលរួមកិច្ចប្រជុំការងារសំខាន់ៗរបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា និងពិធីផ្សេងៗ ចំនួន៤លើក។

- បានរៀបចំ និងចាត់ចែងបញ្ជូនសារលិខិតជូនពរ និងអបអរសាទររបស់ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ក្រាបបង្គំទូលថ្វាយ **សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ** ព្រះវររាជមាតាជាតិខ្មែរ និងជូនឥស្សរជនជាន់ខ្ពស់ជានារី ក្នុងឱកាសនៃការប្រារព្ធខួបអនុស្សាវរីយ៍លើកទី១១៤ នៃទិវាអន្តរជាតិនារី ៨ មីនា ឆ្នាំ២០២៥។
- បានរៀបចំ និងចាត់ចែងបញ្ជូនសារលិខិតអបអរសាទររបស់ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា គោរពជូន **សម្តេចពិជ័យសេនា ទៀ បាញ់** និង **សម្តេចកិត្តិសង្គហបណ្ឌិត ម៉ែន សំអន** ឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ក្នុងឱកាសដែល **ព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ** នៃព្រះរាជាណាចក្រកម្ពុជា ត្រាស់បង្គាប់ដំឡើងឋានន្តរសក្តិ ថ្នាក់ នាយឧត្តមសេនីយ៍ផុតលេខ ផ្កាយមាស៥នៃកងយោធពលខេមរភូមិន្ទ។

- បានរៀបចំ និងចាត់ចែងបញ្ជូនសារលិខិតជូនពររបស់ថ្នាក់ដឹកនាំព្រឹទ្ធសភា ក្នុងឱកាសនៃពិធីចម្រើនជន្មាយុ គោរពជូន៖
    - **ឯកឧត្តម វង សូត** អនុប្រធានទី២រដ្ឋសភា និង
    - **ឯកឧត្តម ជា សុផារ៉ា** ឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា។
- បានរៀបចំ និងចាត់ចែងបញ្ជូនសារលិខិតរំលែកទុក្ខរបស់ថ្នាក់ដឹកនាំ សមាជិក សមាជិកា ព្រឹទ្ធសភា និងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា គោរពជូន **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ប្រមុខរដ្ឋស្តីទី** និងក្រុមគ្រួសារ ចំពោះមរណភាពរបស់ **ឯកឧត្តមអ្នកឧកញ៉ា ឧត្តមមេត្រីវិសិដ្ឋ ហ៊ុន សាន** រដ្ឋលេខាធិការក្រសួងសាធារណការ និងដឹកជញ្ជូន និងជាបងប្រុសបង្កើត **សម្តេចតេជោ**។
- បានធ្វើបទបង្ហាញស្តីពី "រចនាសម្ព័ន្ធ តួនាទី ភារកិច្ច និងសាវតាររបស់ព្រឹទ្ធសភា" ប្រគេនព្រះសង្ឃ និងជូនសាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ និស្សិត និងសិស្សានុសិស្សនៃសាកលវិទ្យាល័យអាស៊ីអឺរ៉ុប និងសាលាបញ្ញាសាស្ត្រអន្តរជាតិសាខាទី៦ ចំនួន១៥១នាក់។
- បានរៀបចំអំណោយ ចំនួន៣០កញ្ចប់ ជូនគណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ និងអន្តរជាតិ និង
- បានទទួលពាក្យបណ្តឹង ចំនួន១២បណ្តឹង បញ្ជូនពាក្យបណ្តឹងចេញទៅក្រសួង ខេត្ត និងស្ថាប័នពាក់ព័ន្ធ ចំនួន១១បណ្តឹង បញ្ជូនពាក្យបណ្តឹងទៅក្រុមមេធាវីស្ម័គ្រចិត្តសម្តេចតេជោសែន ចំនួន ១បណ្តឹង ទទួលលិខិតឆ្លើយតបពីការដោះស្រាយពីក្រសួង ស្ថាប័នពាក់ព័ន្ធ ចំនួន១បណ្តឹង ធ្វើកំណត់បង្ហាញពាក្យបណ្តឹង ចំនួន១២បណ្តឹង កំពុងពិនិត្យសិក្សា ចំនួន១២បណ្តឹង តម្កល់ទុកមិនចាត់ការ ចំនួន៧បណ្តឹង ផ្តល់ព័ត៌មានទៅម្ចាស់បណ្តឹង ចំនួន១៩បណ្តឹង និងទទួលឯកសារជូនជ្រាបពីក្រសួង ស្ថាប័នពាក់ព័ន្ធចម្លងជូនមកគណៈកម្មការ ចំនួន៦បណ្តឹង។

## ៣-មុខងារសហប្រតិបត្តិការអន្តរជាតិ

- បានរៀបចំចាត់ចែង និងផ្តល់សេវាជូនប្រមុខរដ្ឋស្តីទី និងថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា៖

❖ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ប្រមុខរដ្ឋស្តីទី៖**

- បានទទួលសារតាំងពី **ឯកឧត្តម ធុល ត្រៃស្វ៉ាត់** ឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាពនៃព្រះរាជាណាចក្រថៃឡង់ដ៍ នៅវិមានព្រឹទ្ធសភា។
- បានអនុញ្ញាតឱ្យភ្ញៀវអន្តរជាតិ ចូលជួបសម្តែងការគួរសម នៅវិមានព្រឹទ្ធសភា ចំនួន៤លើក រួមមាន៖
    - **លោកជំទាវ ជាវ ឡេ ឈិង** ឯកអគ្គរដ្ឋទូតនៃសាធារណរដ្ឋសិង្ហបុរី។
    - **ឯកឧត្តម វ៉ាន់ឡាល់វ៉ាវណា បាវីតលុង** ឯកអគ្គរដ្ឋទូតនៃសាធារណរដ្ឋឥណ្ឌា។
    - **ឯកឧត្តម អាណាតូលី បូរ៉ូវីក** ឯកអគ្គរដ្ឋទូតនៃសហព័ន្ធរុស្ស៊ី និង
    - គណៈប្រតិភូកុងស៊ុលកិត្តិយសប្រចាំព្រះរាជាណាចក្រកម្ពុជា ដឹកនាំដោយ **លោកបណ្ឌិត សាឡា អេសា** កុងស៊ុលកិត្តិយសនៃសាធារណរដ្ឋស៊ីប និងជាព្រឹទ្ធបុរសនៃកុងស៊ុលកិត្តិយសប្រចាំព្រះរាជាណាចក្រកម្ពុជា។

- **ឯកឧត្តម អ៊ុច បូររិទ្ធ** អនុប្រធានទី១ព្រឹទ្ធសភា បានអនុញ្ញាតឱ្យគណៈប្រតិភូគណៈកម្មការសម្រាប់ភាពជាអ្នកជិតខាងល្អ មិត្តភាព និងកិច្ចសហប្រតិបត្តិការ(GNFCC) នៃអង្គការសហប្រតិបត្តិការសៀងហៃ ដឹកនាំដោយ **លោកស្រី ឈួយ លី** (Cui Li) អនុប្រធានគណៈកម្មការចូលជួបសម្តែងការគួរសម និងពិភាក្សាការងារ ក្នុងឱកាសដែលលោកស្រីដឹកនាំគណៈប្រតិភូមកបំពេញបេសកកម្មការងារនៅព្រះរាជាណាចក្រកម្ពុជា។

- **ឯកឧត្តមបណ្ឌិត ម៉ុង ឫទ្ធី** ប្រធានគណៈកម្មការទី៣ព្រឹទ្ធសភា **ឯកឧត្តម លេង វី** លេខាធិការគណៈកម្មការទី៣ព្រឹទ្ធសភា និង**ព្រះអង្គម្ចាស់ ស៊ីសុវត្ថិ ធម្មិកោ** សមាជិកគណៈកម្មការទី៣ព្រឹទ្ធសភា៖
  - បានអនុញ្ញាតឱ្យគណៈប្រតិភូជាន់ខ្ពស់ក្រុមហ៊ុនចិន DIMENG GROUP ដឹកនាំដោយ **លោក វ៉ាង ហ្ស៊ី ហេង** (Wang Zhi Heng) អគ្គនាយកក្រុមហ៊ុន DIMENG GROUP ចូលជួបពិភាក្សាការងារ និងសម្តែងការគួរសម ក្នុងគោលបំណងសិក្សាទីផ្សារលក់ទិញជីធម្មជាតិ និងជីគីមី ព្រមទាំងពិនិត្យសិក្សាស្វែងរកទីតាំងដីសម្រាប់សាងសង់រោងចក្រផលិតជី នៅសាលពិសេស៣ វិមានព្រឹទ្ធសភា និង
  - បានអនុញ្ញាតឱ្យគណៈប្រតិភូក្រុមហ៊ុនជប៉ុន Nakanishi Kosan ដឹកនាំដោយ **លោកស្រី អ៊ីស៊ូកូ អ៊ីសេគី** (Etsuko Iseki) ចូលជួបសម្តែងការគួរសម និងពិភាក្សាការងារក្នុងគោលបំណងសិក្សាឈ្វេងយល់ពីវិស័យកសិកម្ម និងពិភាក្សាអំពីការផលិតជីធម្មជាតិ និងជីគីមី នៅសាលពិសេស៣ វិមានព្រឹទ្ធសភា។

- **ឯកឧត្តមបណ្ឌិត ថែម វីឡា** ប្រធានគណៈកម្មការទី៥ព្រឹទ្ធសភា៖
  - បានអញ្ជើញចូលរួមក្នុងកិច្ចប្រជុំតំបន់អាស៊ី-ប៉ាស៊ីហ្វិកនៃសភាប្រើភាសាបារាំង តាមប្រព័ន្ធនិម្មិត ដើម្បីពិភាក្សាអំពីកាលបរិច្ឆេទ និងទីកន្លែងសម្រាប់ត្រៀមរៀបចំមហាសន្និបាតលើកទី១១ នៃតំបន់អាស៊ី-ប៉ាស៊ីហ្វិក(APF) នៅសាលប្រជុំពិសេសកណ្តាល វិមានព្រឹទ្ធសភា។
  - បានអញ្ជើញផ្តល់បទសម្ភាសន៍ជូន **លោក ខៀវ កូឡា** ផលិតករជាន់ខ្ពស់នៃទូរទស្សន៍ CNC ស្តីពី សមិទ្ធផលនានារបស់ព្រឹទ្ធសភា ក្នុងឆ្នាំទី១ នីតិកាលទី៥ ជាពិសេសកិច្ចការការបរទេស និងសហប្រតិបត្តិការអន្តរជាតិ នៅការិយាល័យឯកឧត្តមបណ្ឌិតប្រធានគណៈកម្មការទី៥ វិមានព្រឹទ្ធសភា។
  - បានអនុញ្ញាតឱ្យគណៈប្រតិភូសមាជិកខុទ្ទកាល័យសមាជិកសភាអាម៉េរិក ដឹកនាំដោយ **លោក ប្រេត ហ័រតុន** (Brett Horton) ចូលជួបសម្តែងការគួរសម និងពិភាក្សាការងារអំពីការពង្រឹងទំនាក់ទំនងរវាងស្ថាប័ននីតិប្បញ្ញត្តិនៃសហរដ្ឋអាម៉េរិក និងព្រះរាជាណាចក្រកម្ពុជា នៅសាលប្រជុំគណៈកម្មការទី៥ វិមានព្រឹទ្ធសភា។
  - បានអញ្ជើញចូលរួមពិធីជប់លៀងអបអរសាទរខួបកំណើតរបស់ព្រះចៅអធិរាជជប៉ុន នៅនិវេសនដ្ឋានឯកអគ្គរដ្ឋទូតជប៉ុន រាជធានីភ្នំពេញ និង

- បានអញ្ជើញចូលរួមពិធីបង្ហាញសៀវភៅ "The Kings and Queens of Cambodia: From Ang Duong to Norodom Sihamoni" នៅសារមន្ទីរព្រះស្រីឦសានវរ្ម័ន។

❖ **ឯកឧត្តម អ៊ុំ សារិទ្ធ** ប្រធានគណៈកម្មការទី៩ព្រឹទ្ធសភា៖

- បានអញ្ជើញចូលរួមកិច្ចប្រជុំគណៈកម្មការកិច្ចការសភានៃសភាប្រើភាសាបារាំង (APF) នៅទីក្រុងវៀងចន្ទន៍នៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ។
- បានអនុញ្ញាតឱ្យ **លោកស្រី កូហ្គា អាស៊ូកា** (Koga Asuka) លេខាទី៣ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា ចូលជួបសវនាការការងារ នៅបន្ទប់ឯកឧត្តមប្រធានគណៈកម្មការទី៩ វិមានព្រឹទ្ធសភា និង
- បានអនុញ្ញាតឱ្យ **លោក ភីធូ ឡាញ់** (Pitou Lanh) **លោកស្រី ស៊ីសារ៉ា ទ្រីផាមស៊ាប** (Sisira Trepermsub) និង**លោកស្រី បេនច្រេសស៊ីរី វឌ្ឍនាប៉ានុម** (Benchasiri Wattanapanom) តំណាងក្រុមហ៊ុន Price Waterhouse Coopers ចូលជួបសវនាការការងារ នៅការិយាល័យឯកឧត្តមប្រធានគណៈកម្មការទី៩ វិមានព្រឹទ្ធសភា។

❖ **សម្តេចរាជបុត្រីព្រះអនុជ នរោត្តម អរុណរស្មី** សមាជិកាគណៈកម្មការទី១០ព្រឹទ្ធសភា បានយាងជាកិត្តិយសក្នុងកម្មវិធីសម្តែងរបាំព្រះរាជទ្រព្យ នៅសាធារណរដ្ឋបារាំង។

- សកម្មភាពការងាររបស់ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា៖

❖ **ឯកឧត្តម ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភាបាន៖

- អញ្ជើញចូលរួមអម **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ប្រមុខរដ្ឋស្តីទី** ក្នុងពិធីទទួលសារតាំងពី **ឯកឧត្តម ធុល ត្រៃសូវ៉ាត់** ឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាពនៃព្រះរាជាណាចក្រថៃឡង់ដ៏ នៅវិមានព្រឹទ្ធសភា។
- អញ្ជើញចូលរួមអម **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ប្រមុខរដ្ឋស្តីទី** ក្នុងជំនួបសម្តែងការគួរសម ជាមួយភ្ញៀវអន្តរជាតិនានា នៅវិមានព្រឹទ្ធសភា ចំនួន៤លើក។
- អញ្ជើញចូលរួមពិធីជប់លៀង Cocktail Reception ក្នុងឱកាសអបអរសាទរទិវាអន្តរជាតិហ្វ្រង់កូហ្វូនី ឆ្នាំ២០២៥ នៅសណ្ឋាគារសូហ្វីតែលភ្នំពេញភូគីត្រា និង
- ទទួលជួប **ឯកឧត្តម សាន់តូ ដាម៉ូស៊ូម៉ាតូ** ឯកអគ្គរដ្ឋទូតនៃសាធារណរដ្ឋឥណ្ឌូណេស៊ី ប្រចាំព្រះរាជាណាចក្រកម្ពុជា ដើម្បីពិភាក្សាការងារ និងផ្លាស់ប្តូរយោបល់លើកិច្ចសហប្រតិបត្តិការនានា នៅបន្ទប់ប្រជុំឯកឧត្តមអគ្គលេខាធិការ វិមានព្រឹទ្ធសភា។

- បានរៀបចំ និងចាត់ចែងបញ្ជូនសារលិខិតចូលរួមរំលែកទុក្ខរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ប្រមុខរដ្ឋស្តីទី** គោរពជូន **លោកជំទាវ ផែថងថាន ស៊ីណាវ៉ាត្រា នាយករដ្ឋមន្ត្រី** នៃព្រះរាជាណាចក្រថៃឡង់ដ៏ និង**ឯកឧត្តមនាយឧត្តមសេនីយ៍ជាន់ខ្ពស់ មីន អោង ឡាំង** ប្រធានក្រុមប្រឹក្សារដ្ឋនៃសាធារណរដ្ឋសហភាពមីយ៉ាន់ម៉ា នូវសោកនាដកម្មនៃការបំផ្លិចបំផ្លាញយ៉ាងច្រើន រួមទាំងការបាត់បង់អាយុជីវិតមនុស្ស និងការរងរបួស ដោយសារគ្រោះធម្មជាតិ

រញ្ជួយដីធ្ងន់ធ្ងរ នៅរាជធានីបាងកកនៃព្រះរាជាណាចក្រថៃឡង់ដ៏ និងតំបន់ម៉ាន់ដាឡេនៃសាធារណរដ្ឋសហភាពមីយ៉ាន់ម៉ា។

- បានរៀបចំ និងចាត់ចែងបញ្ជូនសារលិខិតចូលរួមរំលែកនូវសមានទុក្ខរបស់ **ឯកឧត្តម អ៊ុច បូរិទ្ធ** ប្រធានស្ដីទីព្រឹទ្ធសភា គោរពជូន **ឯកឧត្តម មង្គល ស៊ុរ៉ះសច្ចៈ** ប្រធានព្រឹទ្ធសភានៃព្រះរាជាណាចក្រថៃឡង់ដ៏ នូវសោកនាដកម្មនៃការបំផ្លិចបំផ្លាញយ៉ាងច្រើន រួមទាំងការបាត់បង់អាយុជីវិតមនុស្ស និងការរងរបួស ដោយសារគ្រោះធម្មជាតិរញ្ជួយដីធ្ងន់ធ្ងរ នៅរាជធានីបាងកកនៃព្រះរាជាណាចក្រថៃឡង់ដ៏។
- បានចាត់ចែងបញ្ជូនសារលិខិតថ្លែងអំណរគុណរបស់ **លោកជំទាវបណ្ឌិត ម៉ាតា ម៉ាត្រៃ** អនុប្រធានទី១រដ្ឋសភានៃប្រទេសហុងគ្រី គោរពជូន **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា ដែល **សម្ដេចតេជោ** បានអនុញ្ញាតឱ្យ **លោកជំទាវបណ្ឌិត** ចូលជួបសម្ដែងការគួរសម ក្នុងអំឡុងពេលទស្សនកិច្ចផ្លូវការនៅព្រះរាជាណាចក្រកម្ពុជា និង
- បានសហការ និងទាក់ទងជាមួយស្ថានទូតចិន ដៃគូអភិវឌ្ឍន៍ក្រៅប្រទេស មូលនិធិចិនដើម្បីអភិវឌ្ឍន៍ជនបទ(CFRD) មជ្ឈមណ្ឌលស្រាវជ្រាវច្បាប់ចិន-អាស៊ាន(CALRC) មជ្ឈមណ្ឌលឯកសារច្បាប់កម្ពុជា បណ្ណសារដ្ឋានជាតិ បណ្ណាល័យ និងក្រសួង ស្ថាប័ននានា ដើម្បីសម្របសម្រួលកិច្ចសហប្រតិបត្តិការអន្តរជាតិ ការស្នើសុំអាហារូបករណ៍ រៀបចំវគ្គបណ្ដុះបណ្ដាល ការស្វែងរកកៀរគរជំនួយ ព្រមទាំងការរៀបចំកម្មវិធីផ្សេងៗ។

## ៤-មុខងារអភិវឌ្ឍន៍ស្ថាប័ន

### ៤.១-សកម្មភាពការងាររបស់ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

- **ឯកឧត្តម ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភាបាន៖
  - អញ្ជើញដឹកនាំកិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រចាំខែកុម្ភៈ និងទិសដៅការងារខែមីនា ឆ្នាំ២០២៥ នៅសាលសិក្ខាសាលាខាងជើង វិមានព្រឹទ្ធសភា។
  - អញ្ជើញដឹកនាំកិច្ចប្រជុំគណៈកម្មការពិនិត្យ និងវាយតម្លៃដំឡើងថ្នាក់បៀវត្សមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា តាមវេនជ្រើសរើស និងតាមវេនអតីតភាព សម្រាប់ឆ្នាំ២០២៥ នៅបន្ទប់ប្រជុំឯកឧត្តមអគ្គលេខាធិការ វិមានព្រឹទ្ធសភា និង
  - អញ្ជើញដឹកនាំកិច្ចប្រជុំផ្ទៃក្នុងជាមួយឯកឧត្តមអគ្គលេខាធិការរង អគ្គនាយក អគ្គនាយិកានៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា នៅបន្ទប់ប្រជុំឯកឧត្តមអគ្គលេខាធិការ វិមានព្រឹទ្ធសភា។

### ៤.២-ការងាររដ្ឋបាល និងហិរញ្ញវត្ថុ

- បានបើកប្រាក់បៀវត្ស ប្រាក់បំណាច់មុខងារបន្ថែម ប្រាក់ឧបត្ថម្ភពិនិត្យ និងព្យាបាលជំងឺ ប្រាក់ឧបត្ថម្ភធ្វើដំណើរ និងសេវាទំនាក់ទំនងប្រចាំខែមីនា ឆ្នាំ២០២៥ និងប្រាក់ឧបត្ថម្ភផ្សេងៗ ជូនសមាជិកសមាជិកាព្រឹទ្ធសភា និងថ្នាក់ដឹកនាំ មន្ត្រីរាជការ បុគ្គលិកជាប់កិច្ចសន្យា មន្ត្រីនគរបាលសន្តិសុខ ជំនួយការផ្ទាល់ អ្នកបើកបររថយន្ត និងនិវត្តជននៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា តាមរយៈប្រព័ន្ធធនាគារ។

- បានបង្វែរប្រាក់វិភាគទានជូនអង្គភាពបេឡាជាតិសន្តិសុខសង្គម (ប.ស.ស) របស់ថ្នាក់ដឹកនាំ មន្ត្រីរាជការ និងបុគ្គលិកជាប់កិច្ចសន្យានៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំខែមីនា ឆ្នាំ២០២៥។
- បានស្នើសុំបុរេប្រទាន និងឥណទានបន្ថែម សម្រាប់ដឹកនាំគណៈប្រតិភូព្រឹទ្ធសភាកម្ពុជា អញ្ជើញចូលរួមមហាសន្និបាតសហភាពអន្តរសភាលើកទី១៥០ និងកិច្ចប្រជុំពាក់ព័ន្ធ នៅទីក្រុងតាស្កិន ប្រទេសអ៊ូសបេគីស្ថាន។
- បានស្នើសុំឥណទានបន្ថែមលើអនុគណនី (៦៤០៥៤) សម្រាប់ចំណាយបើកផ្តល់ជូននិវត្តជនជាសមាជិកព្រឹទ្ធសភា សម្រាប់ឆ្នាំ២០២៥ និងអនុគណនី (៦៤០១៦) សម្រាប់ចំណាយបើកផ្តល់ជូនទីប្រឹក្សា នាយក នាយករង ជំនួយការ និងសមាជិកខុទ្ទកាល័យថ្នាក់ដឹកនាំព្រឹទ្ធសភាសម្រាប់ឆមាសទី២ ឆ្នាំ២០២៥។
- បានបោះផ្សាយអាណត្តិសម្រាប់ត្រីមាសទី២ ជំពូក៦០, ៦១, ៦២ និងជំពូក៦៤ ទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។
- បានផ្តល់សេវាថវិកាជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចំនួន៤៥សំណើ ព្រមទាំងបានទូទាត់ការចំណាយផ្សេងៗ ចំនួន៦៥សំណើ។
- បានដោះស្រាយសំណើផ្គត់ផ្គង់វត្ថុអនុស្សាវរីយ៍ គ្រឿងបរិក្ខារ ប្រេងឥន្ធនៈ សម្ភារអនាម័យ សម្ភារការិយាល័យ ភេសជ្ជៈ និងអាហារសម្រន់សម្រាប់បម្រើដល់កិច្ចប្រជុំ សិក្ខាសាលា និងកម្មវិធីផ្សេងៗ ចំនួន៣៩សំណើ។
- បានថតចម្លងឯកសារ ចំនួន៣,៤០៧ច្បាប់ ចងក្រងធ្វើជាសៀវភៅ ចំនួន២ក្បាល ប្រើប្រាស់ក្រដាសអស់ ចំនួន១៩,៦៣៤សន្លឹក។
- បានផ្តល់សេវាដឹកជញ្ជូនសម្រាប់ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចុះបំពេញបេសកកម្ម នៅតាមបណ្តាភូមិភាគទាំង៨ ចំនួន៦១លើក ស្មើនឹង១៨៤នាក់។
- បានរៀបចំ បោសសម្អាត តុបតែងលម្អសាល តាំងលម្អផ្កាមុខអគារក្រហម និងសាលជំនួបភ្ញៀវ ព្រមទាំងផ្តល់សេវាបម្រើភេសជ្ជៈ ក្នុងកិច្ចប្រជុំ និងកម្មវិធីផ្សេងៗ ចំនួន២៨លើក ស្មើនឹង១,១៩៥នាក់។
- បានទទួលលិខិតចូល ចំនួន៣៤៧ច្បាប់ និងបញ្ជូនលិខិតចេញទៅក្រសួង-ស្ថាប័នពាក់ព័ន្ធនានា ចំនួន៣៩៤ច្បាប់។
- បានធ្វើលិខិតបេសកកម្មជូនសមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចំនួន១១ច្បាប់ ស្មើនឹង៤៨នាក់ និងលិខិតអនុញ្ញាតច្បាប់ជូនសមាជិក សមាជិកាព្រឹទ្ធសភា ចំនួន១៤ច្បាប់។
- បានចុះសួរសុខទុក្ខមន្ត្រីរាជការមានជំងឺ លំហែមាតុភាព និងនិវត្តជននៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចំនួន៨នាក់។

- បានកែលម្អសួនច្បារ កាត់តម្រឹមស្មៅ មែកឈើ និងផ្កានានា ចំនួន១៥លើក និងបានដាំដើមជ្រៃ ដើមឫស្សី ចំនួន១៦២ដើម/គុម្ព ព្រមទាំងបានសម្អាតបរិស្ថាន អនាម័យតាមអគារធ្វើការ និង ក្នុងបរិវេណព្រឹទ្ធសភាជាប្រចាំ។
- បានធ្វើបញ្ជីស្ថិតិមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំខែមីនា រួមមាន៖
    - មន្ត្រីរាជការក្របខ័ណ្ឌ ចំនួន៧២១នាក់ (ប្រុស៤៣០នាក់ ស្រី២៩១នាក់)។
    - បុគ្គលិកជាប់កិច្ចសន្យា ចំនួន៨៧នាក់ (ប្រុស៥២នាក់ ស្រី៣៥នាក់)។
    - មន្ត្រីរាជការមានមុខតំណែងគ្រប់គ្រង ចំនួន៤៩៦នាក់ (ប្រុស៣១១នាក់ ស្រី១៨៥នាក់)។
    - មន្ត្រីរាជការស្ថិតក្នុងភាពទំនេរគ្មានបៀវត្ស ចំនួន១២នាក់ និង
    - មន្ត្រីរាជការព្យួរនៅក្រៅក្របខ័ណ្ឌដើម ចំនួន៥នាក់។
- បានធ្វើសេចក្តីសម្រេច ចំនួន៨ច្បាប់ និងលិខិតបង្គាប់ការ ចំនួន៦ច្បាប់។
- បានធ្វើតារាងបញ្ជាក់ប្រាក់បៀវត្ស ប្រាក់បំណាច់ផ្សេងៗ លិខិតផ្តត់ផ្គង់ និងវិញ្ញាបនបត្របញ្ជាក់ រយៈពេលបំពេញការងាររដ្ឋ ចំនួន១១ច្បាប់។
- បានធ្វើបញ្ជីរាយនាមមន្ត្រីរាជការស្នើសុំប្រាក់វិភាជន៍គ្រួសារ (កូន ចំនួន៥នាក់) ប្រចាំខែមីនា ឆ្នាំ២០២៥។
- បានធ្វើបច្ចុប្បន្នភាពព័ត៌មានជីវប្រវត្តិមន្ត្រីរាជការក្របខ័ណ្ឌនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា។
- បានបញ្ជូនមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចំនួន១នាក់ ចូលរួមវគ្គបណ្តុះបណ្តាលស្តីពី ការទូតសភា (ជំនាន់ទី៧) នៅមជ្ឈមណ្ឌលសភាអាស៊ី។
- បានតាមដាន និងយកចិត្តទុកដាក់ក្នុងដំណើរការកសាងអគារថ្មីកម្ពស់៤ជាន់ ដែលជាគំនិតផ្តួចផ្តើម ដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា ព្រមទាំងការងារ សាងសង់ ជួសជុល កែលម្អអគារ លើកកម្ពស់បរិស្ថាន អនាម័យ ឱ្យបានស្អាត និងស្រស់បំព្រង ជាពិសេសការងារសន្តិសុខ សណ្តាប់ធ្នាប់ ជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និង មន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ទទួលបានផាសុកភាព សុវត្ថិភាព និងបរិយាកាស ការងារល្អ។
- ការងារសាងសង់សំណង់ថ្មីៗ ជួសជុលកែលម្អអគារ និងហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ រួមមាន៖
    - បានជួសជុលពិដាន នៅនាយកដ្ឋានស្រាវជ្រាវកិច្ចការអន្តរជាតិ។
    - បានគាស់ការ៉ូបាត និងរៀបការ៉ូថ្មីឡើងវិញ នៅបន្ទប់សិក្សាអគារជប៉ុន។
    - បានប្តូរហ្វុងអក្សរ Background ឈ្មោះរបស់គណៈកម្មការ នៅបន្ទប់ប្រជុំគណៈកម្មការទី៤ ព្រឹទ្ធសភា និង
    - បានសម្អាតទទឹក និងដំបូលនៅតាមអគារថ្នាក់ដឹកនាំព្រឹទ្ធសភា សាលប្រជុំ និងអគារ D.E.F។
- បានជួសជុលកែលម្អហេដ្ឋារចនាសម្ព័ន្ធអគារ បណ្តាញទឹក បណ្តាញអគ្គិសនី ត្រួតពិនិត្យដំណើរយន្ត កំចាត់សត្វកណ្តៀរ រៀបចំ និងផ្លាស់ប្តូរគ្រឿងអគ្គិសនី គ្រឿងអេឡិចត្រូនិច គ្រឿងសង្ហារិម

ប្រមូលសម្ភារខូច បិទលេខកូដសម្ភារសារពើភ័ណ្ឌ និងបំពាក់សម្ភារការិយាល័យជូនអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងជួសជុលហេដ្ឋារចនាសម្ព័ន្ធផ្សេងៗទៀតក្នុងបរិវេណព្រឹទ្ធសភា ចំនួន១៦២គ្រឿង/លើក។

- បានរៀបចំចងក្រងសៀវភៅបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ ឆ្នាំគោល (ឆ្នាំ២០២៤) របស់ព្រឹទ្ធសភា ចំនួន១៨ក្បាល។
- បានរៀបចំបែបបទជម្រះបញ្ជីអគារចាស់ដើម្បីយកទីតាំងសម្រាប់សាងសង់អគារថ្មីនៃព្រឹទ្ធសភា ចំនួន៣អគារ។
- បានរៀបចំបែបបទឯកសារស្នើសុំគោលការណ៍ប្រគល់រថយន្តជូនអតីតប្រធានគណៈកម្មការ ចំនួន៧គ្រឿង។
- បានធ្វើរបាយការណ៍ស្តីពី លទ្ធផលការងាររបស់ព្រឹទ្ធសភា ប្រចាំខែមីនា ឆ្នាំ២០២៥ ទូលថ្វាយ **ព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ**នៃព្រះរាជាណាចក្រកម្ពុជា។
- បានធ្វើបទបង្ហាញ និងរបាយការណ៍ស្តីពី ការប្រជុំបូកសរុបលទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំខែមីនា ឆ្នាំ២០២៥ និង
- បានធ្វើរបាយការណ៍ស្តីពី លទ្ធផលការងាររបស់ព្រឹទ្ធសភា និងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំខែមីនា ឆ្នាំ២០២៥ ព្រមទាំងបានផ្សព្វផ្សាយលើគេហទំព័រព្រឹទ្ធសភា និងផ្ញើជូនក្រសួង-ស្ថាប័នពាក់ព័ន្ធនានា។

### ៤.៣-ការងារសេវាច្បាប់៖

- បានទទួលព្រះរាជក្រម ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស សេចក្តីជូនដំណឹង និងលិខិតផ្សេងៗ ចំនួន៧ច្បាប់ ពីក្រសួង និងស្ថាប័ននានា។
- បានធ្វើកំណត់បង្ហាញគោរពជូន **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា ជ្រាបអំពីការតែងតាំង និងជ្រើសរើសសមាជិកថ្មីនៃក្រុមប្រឹក្សាធម្មនុញ្ញ ចំនួន៣រូប ជំនួសឱ្យសមាជិកចាស់នៃក្រុមប្រឹក្សាធម្មនុញ្ញ ដែលត្រូវចប់អាណត្តិ នៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៥ ខាងមុខនេះ។
- បានធ្វើបច្ចុប្បន្នភាពកម្មវិធីចុះបេសកកម្មរបស់គណៈកម្មការទាំង១០ព្រឹទ្ធសភា នៅចន្លោះសម័យប្រជុំលើកទី២ និងលើកទី៣ នីតិកាលទី៥។
- បានបូកសរុបសេចក្តីព្រាងច្បាប់ និងសេចក្តីស្នើច្បាប់ដែលព្រឹទ្ធសភាបានពិនិត្យ ហើយឱ្យយោបល់ក្នុងឆ្នាំ២០២៤ និងឆ្នាំ២០២៥។
- បានទទួល និងប្រគល់សៀវភៅច្បាប់ស្តីពី ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៥ ភាគ១ ភាគ២ និងភាគ៣ ជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងអង្គភាពពាក់ព័ន្ធ ចំនួន២៣៤ក្បាល។
- បានផ្តល់សេវារដ្ឋបាល បច្ចេកទេស ព័ត៌មាន ពិធីការ ទំនាក់ទំនងការងារ និងធ្វើរបាយការណ៍ជូនគណៈកម្មការទាំង១០ និងក្រុមនានារបស់ព្រឹទ្ធសភា អញ្ជើញចុះបេសកកម្មនៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្តនានា ព្រមទាំងក្នុងកិច្ចប្រជុំ និងកម្មវិធីផ្សេងៗ ចំនួន២៦៧លើក។
- បានប្រគល់ឯកសារប្រកាសទ្រព្យសម្បត្តិ និងបំណុល ដែលបានពិនិត្យ ចុះបញ្ជី និងប្រថាប់ត្រារបស់អង្គភាពប្រឆាំងអំពើពុករលួយជូនសាមីខ្លួន និងអ្នកតំណាង ដើម្បីរក្សាទុក ចំនួន១៤៧ច្បាប់ និង

- បានពិនិត្យផ្ទៀងផ្ទាត់ឈ្មោះស្ថានបុគ្គលជាប់កាតព្វកិច្ចប្រកាសទ្រព្យសម្បត្តិ និងបំណុល ទទួលការតែងតាំងថ្មី នៅក្រសួង-ស្ថាប័នផ្សេងៗ ចំនួន១នាក់។

### ៤.៤-ការងារស្រាវជ្រាវ៖

- បានស្រាវជ្រាវ និងរៀបចំឯកសារជំនួយស្មារតីលើសេចក្តីព្រាងច្បាប់ ចំនួន២ច្បាប់ រួមមាន៖
    - សេចក្តីព្រាងច្បាប់ស្តីពី ការប្រឆាំងការមិនទទួលស្គាល់ឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ និង
    - សេចក្តីព្រាងច្បាប់ស្តីពី ការចាត់ចែងជាបណ្តោះអាសន្ននូវវត្ថុចាប់យក។
- បានស្រាវជ្រាវ និងរៀបចំឯកសារជំនួយស្មារតីជាបឋមស្តីពី បញ្ហាប្រឈម និងបទដ្ឋានគតិយុត្តពិបាកអនុវត្តនៅភូមិភាគទី៦។
- បានតាមដាន និងសិក្សាលើព្រឹត្តិបត្រស្ថិតិបំណុលសាធារណៈកម្ពុជា និងរបាយការណ៍របស់ធនាគារជាតិនៃកម្ពុជា។
- បានតាមដានការរៀបចំសេចក្តីព្រាងច្បាប់ស្តីពី៖
    - ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៦ និង
    - ការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៤។
- បានសិក្សាអំពី៖
    - ថវិការដ្ឋ ថវិកាថ្នាក់ក្រោមជាតិ តុល្យការថវិកា ការខ្ចី និងស្ថានភាពបំណុលសាធារណៈ និងហានិភ័យសារពើពន្ធ ក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ច ការប្រៀបធៀបបរិបទប្រទេសនៅក្នុងតំបន់អាស៊ាន។
    - ការអនុវត្តការធ្វើកំណែទម្រង់គោលនយោបាយចំណូល-ចំណាយ និង
    - យុទ្ធសាស្ត្រស្តីពី ការគ្រប់គ្រងបំណុលសាធារណៈឆ្នាំ២០២៤-២០២៨។
- បានសង្ខេបយុទ្ធសាស្ត្រកៀរគរចំណូលរបស់រាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា។
- បន្តចងក្រងទិន្នន័យលិខិតបទដ្ឋានគតិយុត្តតាមវិស័យរបស់គណៈកម្មការនានា។
- បានចងក្រងឯកសារយុទ្ធសាស្ត្រជាតិស្តីពី ការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធឆ្នាំ២០២៣-២០២៨។
- បានបកប្រែ និងសង្ខេបព័ត៌មានសភាបញ្ចូលក្នុងសម្រង់សង្ខេបព័ត៌មានសំខាន់ៗប្រចាំថ្ងៃ ចំនួន១៩០ព័ត៌មាន និង
- បានស្រង់ឯកសារពីក្នុងរាជកិច្ច និងចាត់ថ្នាក់ទៅតាមវិស័យច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត (រាជកិច្ចពីលេខ ៧-១១ ឆ្នាំ២០២៤)។

### ៤.៥-ការងារព័ត៌មាន និងទំនាក់ទំនងសាធារណៈ៖

- បានផលិត និងផ្សព្វផ្សាយខ្សែវីដេអូព័ត៌មានស្តីពី សកម្មភាពការងាររបស់ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងថ្នាក់ដឹកនាំនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងលទ្ធផលការងាររបស់ព្រឹទ្ធសភា ចំនួន២២លើក។
- បានថត និងផ្សព្វផ្សាយព័ត៌មានស្តីពី សកម្មភាពការងាររបស់ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា

និងថ្នាក់ដឹកនាំនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងសកម្មភាពការងាររបស់ព្រឹទ្ធសភា និងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា តាមប្រព័ន្ធ Facebook, Instagram, X ( Former Twitter ), Youtube និងTiktok ចំនួន១,៥៤៣លើក។

- បានបញ្ចូលព័ត៌មានស្ដីពី សកម្មភាពការងាររបស់ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងថ្នាក់ដឹកនាំនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងលទ្ធផលការងាររបស់ព្រឹទ្ធសភា និងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា លើគេហទំព័រព្រឹទ្ធសភា ចំនួន២៥២សកម្មភាព។
- បានប្រមូល និងផ្សព្វផ្សាយព័ត៌មានក្នុងឆានែលតេឡេក្រាម ព័ត៌មានប្រចាំថ្ងៃព្រឹទ្ធសភា ចំនួន ៩២២ ប្រធានបទ។
- បានអញ្ជើញអ្នកសារព័ត៌មាននៃទូរទស្សន៍ជាតិកម្ពុជា ចូលយកព័ត៌មាន ក្នុងកិច្ចប្រជុំសំខាន់ៗរបស់ព្រឹទ្ធសភា ជំនួបសម្ដែងការគួរសម ពិភាក្សាការងារជាមួយភ្ញៀវជាតិ-អន្តរជាតិ និងកម្មវិធីផ្សេងៗ ចំនួន១០លើក។
- បានតាំងពិព័រណ៍រូបភាពសកម្មភាពរបស់ថ្នាក់ដឹកនាំព្រឹទ្ធសភា សមាជិក សមាជិកាគណៈកម្មការទាំង១០ ក្រុមភូមិភាគទាំង៨ និងក្រុមយន្តការនានារបស់ព្រឹទ្ធសភា នៅខ្លោងទ្វារធំព្រឹទ្ធសភា ចំនួន ១៣លើក។
- បានរៀបចំផលិតទស្សនាវដ្ដីព្រឹទ្ធសភា ប្រចាំខែមីនា ឆ្នាំ២០២៥ ចំនួន៦០០ក្បាល។
- បានស្រាវជ្រាវ ចងក្រង និងផ្សព្វផ្សាយព័ត៌មានស្ដីពី បច្ចេកវិទ្យាឌីជីថល ចំនួន២០៥ចំណងជើង។
- បានចុះត្រួតពិនិត្យ តាមដានប្រព័ន្ធណេតវើក អ៊ីនធឺណែត ពង្រឹងពង្រីកការផ្គត់ផ្គង់ ថែទាំ និងជួសជុលឧបករណ៍ សម្ភារ បរិក្ខារបច្ចេកទេស ព្រមទាំងដោះស្រាយបញ្ហាផ្សេងៗដែលពាក់ព័ន្ធនឹងជំនាញបច្ចេកវិទ្យាព័ត៌មាន ចំនួន១២៥គ្រឿង/លើក។
- បានរៀបចំប្រព័ន្ធស្ទូឌីយ៉ូ ប្រព័ន្ធសំឡេង ប្រព័ន្ធមេក្រូហ្វូន ប្រព័ន្ធរូបភាព ប្រព័ន្ធកាមេរ៉ា ប្រព័ន្ធប្រជុំនិម្មិត ឬប្រព័ន្ធប្រជុំពីចម្ងាយ( Digital ) ព្រមទាំងបានរចនាផ្ទាំង Backdrop Background និងបញ្ចាំងផ្ទាំង LED ក្នុងកិច្ចប្រជុំសំខាន់ៗរបស់ព្រឹទ្ធសភា ជំនួបសម្ដែងការគួរសម និងពិភាក្សាការងារជាមួយភ្ញៀវជាតិ-អន្តរជាតិ ចំនួន៥៣លើក។
- បានទទួលឯកសារ ទស្សនាវដ្ដី សៀវភៅច្បាប់ និងសៀវភៅជំនាញផ្សេងៗ ចំនួន៣៥ក្បាល ព្រមទាំងបានចុះបញ្ជីសៀវភៅ បោះត្រាបិទប័ណ្ណខ្ចី និងសងសៀវភៅ ចំនួន៣៤ក្បាល។
- បានផ្សព្វផ្សាយឯកសាររបស់ព្រឹទ្ធសភា អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ឯកសារច្បាប់ ឯកសារជំនាញផ្សេងៗ និងសៀវភៅជា E-Book តាមគេហទំព័រ www.elibrary.senate.gov.kh ចំនួន ៧,៦៥៣ក្បាល ដែលមានសាធារណជនចូលអាន ចំនួន១,០២៥នាក់ ( ដោយគិតត្រឹមខែមីនា ឆ្នាំ២០២៥ ) និង
- បានទទួលឯកសារពីអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា និងបានរៀបចំចាត់ថែងតម្កល់រក្សាទុកឯកសារនៅបណ្ណសារដ្ឋាន ដោយបានរៀបចំសៀវភៅព្រឹត្តិបត្រព្រឹទ្ធសភា( ស្ទួន ) ឆ្នាំ២០១២ ចំនួន៩០២ក្បាល ត្រួតពិនិត្យបញ្ចូលមាតិកាលិខិត និងមាតិកាសំណុំលិខិតទៅក្នុងប្រព័ន្ធកុំព្យូទ័រ ចំនួន៩៥សំណុំលិខិត។

**៤.៦-ការងារពិធីការ និងទំនាក់ទំនងអន្តរជាតិ៖**

- បានរៀបចំចាត់ចែង និងសម្របសម្រួលជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចូលរួមកិច្ចប្រជុំ ជំនួបសម្តែងការគួរសម ពិភាក្សាការងារ និងពិធីផ្សេងៗ ចំនួន២៥លើក។
- បានរៀបចំសារលិខិតថ្វាយព្រះពរ លិខិតជូនពរ និងកន្ត្រកផ្កា របស់ថ្នាក់ដឹកនាំព្រឹទ្ធសភា និងថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ទូលថ្វាយ**ព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ** និងជូនឥស្សរជនជាន់ខ្ពស់ជាតិ-អន្តរជាតិ ថ្នាក់ដឹកនាំតាមក្រសួង-ស្ថាប័ននានា ចំនួន២៤លិខិត និងចំនួន១៤កន្ត្រក។
- បានរៀបចំបែបបទ និងកសាងឯកសារនានា ជូនថ្នាក់ដឹកនាំព្រឹទ្ធសភា និងថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចំនួន៩ច្បាប់/លើក។
- បានផលិត និងផ្សព្វផ្សាយ "ព្រឹត្តិបត្រព័ត៌មានកិច្ចការអន្តរជាតិ ប្រចាំខែមីនា ឆ្នាំ២០២៥" ចំនួន១ច្បាប់ និង
- បានរៀបចំឯកសារជំនួយស្មារតីស្តីពី កិច្ចសហប្រតិបត្តិការរវាងព្រឹទ្ធសភាកម្ពុជា ជាមួយសភាអាល្លឺម៉ង់ សភាឥណ្ឌា និងអង្គការសម្ព័ន្ធពិភពឥស្លាម(MWL)។

**៤.៧-ការងារអគ្គាធិការដ្ឋាន៖**

- បានប្រជុំពិភាក្សាការងារអំពីលទ្ធផលការងារសង្គមកិច្ច និងការផ្តល់សេវាជាមួយអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំខែមីនា ឆ្នាំ២០២៥ ចំនួន២២លើក។
- បានប្រមូល និងរៀបចំរបាយការណ៍ជាមួយនាយកដ្ឋានផែនការ និងសរុប នាយកដ្ឋានគ្រប់គ្រងបុគ្គលិក នាយកដ្ឋានអភិវឌ្ឍន៍ធនធានមនុស្ស និងបណ្ណសារដ្ឋានស្តីពី ការអនុវត្តផែនការការងារ និងគោលនយោបាយនានា របស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា។
- បានរៀបចំរបាយការណ៍ស្តីពី លទ្ធផលការងាររបស់នាយកដ្ឋានត្រួតពិនិត្យការងារសង្គមកិច្ច និងការផ្តល់សេវា ប្រចាំខែមីនា ឆ្នាំ២០២៥។
- បានចុះត្រួតពិនិត្យវត្តមានជាក់ស្តែងតាមនាយកដ្ឋាននានា ប្រចាំខែមីនា ឆ្នាំ២០២៥ ចំនួន២លើក ដើម្បីផ្ទៀងផ្ទាត់បញ្ជីវត្តមាន ដែលនាយកដ្ឋានចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានបញ្ជូនមកអគ្គាធិការដ្ឋាន ប្រចាំថ្ងៃ។
- បានបូកសរុប និងធ្វើរបាយការណ៍សម្រង់វត្តមាន ប្រចាំថ្ងៃ ចំនួន៤២លើក ប្រចាំសប្តាហ៍ ចំនួន៤លើក និងប្រចាំខែមីនា ឆ្នាំ២០២៥ ដែលគ្រប់អង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានបញ្ជូនមកអគ្គាធិការដ្ឋាន ប្រចាំថ្ងៃ។
- បានចុះត្រួតពិនិត្យ និងធ្វើរបាយការណ៍ស្តីពី បរិស្ថាន អនាម័យ ការខូចខាតសម្ភារតាមអគារ និងសណ្តាប់ធ្នាប់នៃការចតយានយន្តក្នុងបរិវេណព្រឹទ្ធសភា និង
- បានធ្វើបច្ចុប្បន្នភាពបញ្ជីឈ្មោះមន្ត្រីរាជការតាមអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា។

## II-ទិសដៅការងារខែមេសា ឆ្នាំ២០២៥

### ១- មុខងារនីតិកម្ម

- ត្រៀមរៀបចំប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ និងសម័យប្រជុំព្រឹទ្ធសភាជាវិសាមញ្ញ នីតិកាលទី៥ ដើម្បីពិនិត្យ ហើយឱ្យយោបល់លើសេចក្តីព្រាងច្បាប់ ចំនួន២ច្បាប់៖
    - ១- សេចក្តីព្រាងច្បាប់ស្តីពី ដលផល និង
    - ២-សេចក្តីព្រាងច្បាប់ស្តីពី ការទទួលខុសត្រូវលើផលិតផលមានវិការៈ។
- ត្រៀមរៀបចំកិច្ចប្រជុំអន្តរគណៈកម្មការជាមួយតំណាងរាជរដ្ឋាភិបាល ដើម្បីពិនិត្យ និងសិក្សាលើសេចក្តីព្រាងច្បាប់ ចំនួន២ច្បាប់ និង
- បន្តពិភាក្សារៀបចំសមាជរដ្ឋសភា និងព្រឹទ្ធសភា។

### ២-មុខងារតាមដានការអនុវត្តច្បាប់ និងគោលនយោបាយនានា

- ត្រៀមសហការ និងសម្របសម្រួលការងារជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា ជួបសវនាការជាមួយក្រសួង-ស្ថាប័ន អាជ្ញាធរថ្នាក់ក្រោមជាតិ និងចុះបេសកកម្ម ដើម្បីតាមដានការអនុវត្តច្បាប់ និងគោលនយោបាយនានា នៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្តនានា។

### ៣- មុខងារតំណាង

- ត្រៀមរៀបចំជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា អញ្ជើញចុះជួបសំណេះសំណាល សាកសួរសុខទុក្ខប្រជាពលរដ្ឋ ពិភាក្សាការងារជាមួយអាជ្ញាធរដែនដី ពិនិត្យវឌ្ឍនភាពនៃការអភិវឌ្ឍ នៅថ្នាក់ក្រោមជាតិ ចូលរួមសិក្ខាសាលា វេទិកា កិច្ចប្រជុំនានា និងពិធីផ្លូវការផ្សេងៗ នៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្តនានា។
- ត្រៀមរៀបចំចាត់ចែងបញ្ជូនសារលិខិតជូនពរ គោរពជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ក្នុងឱកាសនៃពិធីបុណ្យចូលឆ្នាំថ្មី ប្រពៃណីជាតិខ្មែរ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩។
- ត្រៀមរៀបចំពិធីបុណ្យចូលឆ្នាំថ្មី ប្រពៃណីជាតិខ្មែរ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ និង
- ត្រៀមទទួលដំណើរទស្សនកិច្ចរបស់សាធារណជន និងសិស្ស និស្សិត ដើម្បីសិក្សាឈ្វេងយល់អំពីរចនាសម្ព័ន្ធ តួនាទី ភារកិច្ចរបស់ព្រឹទ្ធសភា។

### ៤- មុខងារសហប្រតិបត្តិការអន្តរជាតិ

- ត្រៀមផ្តល់សេវាចាំបាច់បម្រើការងារសហប្រតិបត្តិការតំបន់ និងអន្តរជាតិ ការចូលរួមមហាសន្និបាត សិក្ខាសាលា វេទិកានានា កម្មវិធីជំនួប កម្មវិធីផ្លូវការ និងកិច្ចសហប្រតិបត្តិការជាមួយដៃគូនានា។
- ត្រៀមរៀបចំជូនគណៈប្រតិភូជាន់ខ្ពស់ព្រឹទ្ធសភា អញ្ជើញបំពេញទស្សនកិច្ច នៅសាធារណរដ្ឋឥណ្ឌូណេស៊ី សាធារណរដ្ឋប្រជាធិបតេយ្យទីម័រឡេស្តេ និងសាធារណរដ្ឋសង្គមនិយមវៀតណាម និង
- បន្តត្រៀមស្រាវជ្រាវ បកប្រែ និងរៀបចំឯកសារជំនួយស្មារតី សុន្ទរកថាជូនថ្នាក់ដឹកនាំ សមាជិក

សមាជិកាព្រឹទ្ធសភា និងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ជួបជាមួយភ្ញៀវអន្តរជាតិក្នុងជំនួបសវនាការ កិច្ចប្រជុំ និងទស្សនកិច្ចនានា។

**៥- មុខងារអភិវឌ្ឍន៍ស្ថាប័ន**

- ត្រៀមបើកវគ្គបណ្ដុះបណ្ដាលស្ដីពី ជំនាញឌីជីថលចាំបាច់ (Essential Digital Skills) នៅវិទ្យាស្ថានឌីជីថល(IDG) នៃបណ្ឌិត្យសភាបច្ចេកវិទ្យាឌីជីថល (CADT)។
- ត្រៀមបើកវគ្គបណ្ដុះបណ្ដាលស្ដីពី ជំនាញកត់ត្រា និងជំនាញសំខាន់ៗជាច្រើនទៀត។
- បន្តអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធនានារួមមាន ការសាងសង់អគារថ្មី ការជួសជុល ថែទាំ កែលម្អបរិស្ថាន អនាម័យ សួនច្បារ ប្រព័ន្ធអគ្គិសនី ប្រព័ន្ធទឹក ប្រព័ន្ធលូ ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងប្រព័ន្ធសន្តិសុខ ផ្ទៃក្នុងព្រឹទ្ធសភា ប្រកបដោយសុខសុវត្ថិភាព។
- បន្តផ្ដល់សេវាផ្គត់ផ្គង់សម្ភារ ថវិកា មធ្យោបាយដឹកជញ្ជូន ទំនាក់ទំនងជាមួយអាជ្ញាធរថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងសេវាសំខាន់ៗផ្សេងទៀតជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា បំពេញមុខងាររបស់ខ្លួនក្នុងអំឡុងពេលចន្លោះសម័យប្រជុំឱ្យបានទាន់ពេលវេលា និងល្អប្រសើរ និង
- បន្តការចុះសួរសុខទុក្ខមន្ត្រីរាជការលំហែមាតុភាព និងនិវត្តជននៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា។

**III-សេចក្ដីសន្និដ្ឋាន**

ខែមីនា ជាខែទី៣នៃវិស្សមកាលរយៈពេលបីខែរបស់ព្រឹទ្ធសភា អគ្គលេខាធិការដ្ឋាន បានបង្កើនការផ្ដល់សេវាជូនថ្នាក់ដឹកនាំ សមាជិក សមាជិកា គណៈកម្មការ ក្រុមយន្តការនានារបស់ព្រឹទ្ធសភា បំពេញមុខងារតាមដានការអនុវត្តច្បាប់ និងមុខងារតំណាង របស់ខ្លួន ដើម្បីបិទបញ្ចប់ការងារស្របតាមផែនការសកម្មភាពការងាររយៈពេល៣ខែនៃវិស្សមកាល។

ស្ថិតក្នុងបរិបទនេះ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានធ្វើរបាយការណ៍បូកសរុបសកម្មភាព និងលទ្ធផលការងាររយៈពេល៣ខែ របស់ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា គណៈកម្មការ ក្រុមយន្តការនានា ដើម្បីរាយការណ៍ជូនកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ និងកិច្ចប្រជុំពេញអង្គព្រឹទ្ធសភា។

ចំពោះការងារកិច្ចសហប្រតិបត្តិការអន្តរជាតិ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានយកចិត្តទុកដាក់ខ្ពស់ក្នុងការផ្ដល់សេវាជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា បំពេញមុខងារការទូតសភាដោយសម្រេចបានលទ្ធផលកាន់តែល្អប្រសើរ។

ថ្ងៃ[illegible] [illegible] ខែ[illegible] ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី[illegible] ខែមិនា ឆ្នាំ២០២៥

**អគ្គលេខាធិការ**

**ឡាយ សំកុល**